00846886

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / 09 / 2012
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

002/19-09-2007-ECCC/TC
E1/115

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ច័ន្ទ ទី ២៧ ខែ សីហា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ១០២

រៀបចំដោយ: ឌុច ផារី និង Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក ដារ អានសាន, លោក Roger Phillips |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ចាន់ ដារារស្មី, លោក Vincent DE WILDE D'ESTMAEL, លោក Dale LYSAK |
| ជនជាប់ចោទ៖ នួន ជា, អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោម), ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KANAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក គីម ម៉េងឃី, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី Christine MARTINEAU |
| ដើមបណ្តឹងរដ្ឋប្បវេណី៖ អ៊ែម អឿន (TCCP-28) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Eleanor DOYLE-MARKWICK, លោក Yiqiang LIU |

| **<u>ពេលវេលាចូលទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១២.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ២ ម៉ោង និង៤០ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី | ០៩.០៥ | ០៩.០៧ |
| *ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ែម អឿន* (TCCP-28) | សហព្រះរាជអាជ្ញាជាតិ<br>មេធាវីការពារក្តី នួន ជា | ០៩.០៨<br>១១.៤៣ | ១១.៤២<br>១២.០០ |
| ការផ្អាកកិច្ចដំណើរការនីតិវិធីដើម្បីរៀបចំនូវកិច្ចប្រជុំរៀបចំសវនាការ | អង្គជំនុំជម្រះ | ១២.០០ | ១២.០១ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់</u>**

ជនជាប់ចោទ អៀង សារី (៩.០៥) តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់រយៈពេលពេញមួយថ្ងៃ។

**ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន (TCCP-28)**

សហព្រះរាជអាជ្ញាបន្តតាំងសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-28។ បន្ទាប់មក មេធាវីការពារក្តី នួន ជា ចាប់ផ្តើមសួរសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

**ការផ្អាកកិច្ចដំណើរការនីតិវិធីដើម្បីរៀបចំនូវកិច្ចប្រជុំរៀបចំសវនាការ**

អង្គជំនុំជម្រះបានប្រកាសផ្អាកកិច្ចដំណើរការនីតិវិធីនៅម៉ោង ១២.០០ ហើយសម្រេចធ្វើនូវកិច្ចប្រជុំរៀបចំសវនាការនៅពេលរសៀល។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃកិច្ចការផ្ទៃក្នុង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|
| E3/1729 | D22/3963 | 00573967-00573988<br>00751861-00751874<br>00786171-00786194 | [លិខិតបញ្ជាក់ការជំនួសឯកសារ] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អែម អឿន EM Oeun 10-VU-00964<br>[Surrogate Sheet] Civil party application of EM Oeun 10-VU-00964<br>[Feuille remplacée] Demande de constitution de partie civile de EM Oeun 10-VU-00964 | P | 00573978, 00573979 | 00751867 | 00786186 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (០៩.០៥) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ នាំដើមបណ្តឹងរដ្ឋប្បវេណី *អែម អឿន* (TCCP-28) ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញ

ឲ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ។

- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី, នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ អង្គារ ទី ២៨ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ឆារី Roger PHILLIPS